ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ៥៨៦ ក្រ១១"ង"
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ ៩០៣
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ៤៩៨
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ ១៥៥៦
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៩០៣ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ សាសនាឥស្លាម ទីកន្លែងកំណើត[redacted] ខេត្តតាកែវ មានទីលំនៅមុនឃាត់ខ្លួននៅផ្ទះគ្មានលេខ ផ្លូវជាតិលេខ៥ ក្រុមទី៦ ភូមិក សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]សេង (រ) ម្តាយឈ្មោះ [redacted]ណាស់ (រ) ពោះម៉ាយ មានកូន០៥នាក់ ជានីតិជន។

ឃាត់ខ្លួននៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ១២៣៣ "ឆ១" ដ.ឃ.ដ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

លោកមេធាវី[redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី០១ ភូមិ ខ១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ[redacted] សាវ៉ាត ភេទស្រី កើតនៅឆ្នាំ១៩៨៨ មុខរបរនៅផ្ទះ មានអាសយដ្ឋានក្រុមទី១ ភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]អូស្តាឡា ភេទប្រុស កើតនៅឆ្នាំ១៩៥៩ មុខរបរក្រុមប្រឹក្សាខណ្ឌមានអាសយដ្ឋានផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី១ ភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង០០និង៣០នាទី រំលងអធ្រាត្រ ជនជាប់ចោទឈ្មោះ [redacted] កុសល បានអង្គុយហូបស្រាអស់កន្លះដប នៅចំណុចផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី០១ ភូមិខ១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ពេលនោះ ជនជាប់ចោទឈ្មោះ [redacted] កុសល បានដើរទៅបត់ជើងតូច ហើយបានដើរត្រឡប់មកវិញ ចូលមកក្នុងផ្ទះ ឃើញជនរងគ្រោះឈ្មោះ [redacted] សាវើត កំពុងសម្រាន្តលង់លក់នៅលើសាឡុង ។ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] កុសល បានធ្វើសកម្មភាពចាប់អោបថើប និងសង្កត់ពីលើជនរងគ្រោះ។ ពេលនោះ ជនរងគ្រោះឈ្មោះ [redacted] សាវើត បានដឹងខ្លួនទាន់ ក៏ស្រែកឆោរឡោផ្អើលដល់ប្រជាពលរដ្ឋជិតខាង ហើយត្រូវបានឈ្មោះ [redacted] អូស្ការ៉ា ចាប់ជនត្រូវចោទនាំមកប្រគល់ឲ្យសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង រួចសមត្ថកិច្ចបានបង្កសំណុំរឿងបញ្ជូនមកអយ្យការសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ របាយការណ៍សំយោគលេខ០២១/១៩រ.ក.ប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពាររអនីតិជន និងការងារយេនឌ័រ-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៤៩៩ អ.យ.ច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ១៤២៦ អ.យ.ច ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៩៣០ "ធ១" ដ.ដ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយថា៖ កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង០៨យប់ ខ្លួនបានធីកស្រាក្រហមអស់ចំនួន០១ដបតែម្នាក់ឯង ។ បន្ទាប់មកខ្លួនបានចូលទៅក្នុងផ្ទះដើម្បីនោម ហើយក៏បានឃើញជនរងគ្រោះឈ្មោះ [redacted] សាវើត កំពុងដេកនៅលើសាឡុងកំពុងចុចទូរស័ព្ទ ។ ពេលនោះ ខ្លួនបានប្រាប់ជនរងគ្រោះថា "កុំឲ្យលេងហ្វេសប៊ុកច្រើនពេកពីព្រោះម៉ោង១១ជាងយប់ហើយ" ។ ពេលនោះ ជនរងគ្រោះឈ្មោះ [redacted] សាវើត បានស្រែកឲ្យខ្លួនដោយសម្លេងខ្លាំងៗ ស្រាប់តែបងស្រីខ្លួនឈ្មោះ [redacted] រ៉ូហ្សាមី បានដើរចូលមកឃើញ និងបានស្តីបន្ទោសឲ្យខ្លួនជាច្រើនធ្វើឲ្យខ្លួនខឹងក៏បានទាញដំបងវាយធុងបាស់ឲ្យបែកតែម្តង។ ពេលនោះ បងស្រីខ្លួនបានប្តឹងសមត្ថកិច្ចឲ្យឃាត់ ខ្លួន ។ កន្លងមកខ្លួនធ្លាប់សារភាពប្រាប់ជនរងគ្រោះថា "ខ្លួនស្រឡាញ់និងចង់បានជនរងគ្រោះមកធ្វើជាប្រពន្ធរបស់ខ្លួន"។ ប៉ុន្តែត្រូវបានបងស្រីរបស់ខ្លួនហាមមិនឲ្យមានទំនាក់ទំនងជាមួយនឹងជនរងគ្រោះទេ ដោយសារជនរងគ្រោះជាអ្នកជួយ ការងារផ្ទះឲ្យបងស្រីខ្លួន ។ ខ្លួនពុំមានបំណងរំលោភសេពសន្តវៈមកលើជនរងគ្រោះទេ ពីព្រោះខ្លួនអសមត្ថភាពផ្លូវភេទ ។ ប៉ុន្តែខ្លួនគ្រាន់តែបានអោបថើបជនរងគ្រោះប៉ុណ្ណោះ ។ ប្រពន្ធរបស់ខ្លួនបានស្លាប់អស់រយៈពេល៦-៧ឆ្នាំមកហើយ។

-ជនរងគ្រោះឈ្មោះ [redacted] សាវើត បានឆ្លើយថា៖ ខ្លួនសុំបដិសេធចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថាជនជាប់ចោទឈ្មោះ [redacted] កុសល បាននិយាយគំរាមសម្លាប់ខ្លួន និងមិនឲ្យនិយាយទូរស័ព្ទជាមួយមនុស្សប្រុសណាទាំងអស់ ហើយគាត់បានចាប់រំលោភខ្លួនចំនួន០២លើមកនោះ គឺមិនត្រឹមត្រូវទេ ។ តាមពិត នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង២៤និង០០នាទី ជនជាប់ចោទឈ្មោះ [redacted] កុសល គ្រាន់តែស្រវឹងស្រាខ្លាំង និងបានដើរជិតប់ជើងដួលមកលើខ្លួនហើយច្រមុះរបស់គាត់បានមកប៉ះត្រូវថ្ពាល់របស់ខ្លួនដែលកំពុងដេកលក់មួយស្របក់នៅលើសាឡុងក្នុងផ្ទះរបស់ម្ចាស់ផ្ទះឈ្មោះ [redacted] រ៉ូហ្សាមី ។ ពេលនោះ ខ្លួនភ្ញាក់ក៏បានស្រែកក្នុងសម្លេងខ្លាំងតែម្តង ។ ម្ចាស់ផ្ទះឈ្មោះ [redacted] រ៉ូហ្សាមី បានចូលមកស្តីបន្ទោសឲ្យជនជាប់ចោទ ទើបជនជាប់ចោទខឹងក៏បានវាយឥវ៉ាន់នៅក្នុងផ្ទះរបស់ម្ចាស់ផ្ទះ ហើយម្ចាស់ផ្ទះក៏បាន

ប្តឹងសមត្ថកិច្ចឲ្យឃាត់ខ្លួនតែម្តង ។ មូលហេតុដែលខ្លួនប្តឹងថាជនជាប់ចោទមានបំណងរំលោភសេពសន្ថវៈមកលើខ្លួននោះ ដោយសារខ្លួនមានការភ័យខ្លាចជនជាប់ចោទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ម្ចាស់ផ្ទះខ្លួន ។ កន្លងមកខ្លួនក៏ធ្លាប់មានចិត្តលើជនជាប់ចោទឈ្មោះ [redacted] កុសល ដែរ ។ ពេលនេះ ខ្លួនសុំដកពាក្យបណ្តឹងឈប់ប្តឹងជនជាប់ចោទឈ្មោះ [redacted] កុសល ទៀតហើយ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អូស្ណាឡា បានឆ្លើយថា៖ខ្លួនជាបងថ្លៃរបស់ជនជាប់ចោទឈ្មោះ [redacted] កុសល មូលហេតុដែលខ្លួនប្តឹងជនជាប់ចោទឈ្មោះ [redacted] កុសល ដោយសារតែខ្លួនខឹងនឹងជនជាប់ចោទបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន។ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២៤និង០០នាទីជនជាប់ចោទឈ្មោះ [redacted] កុសល បានមកហូបស្រាស្រវឹងតែម្នាក់ឯងនៅក្នុងផ្ទះរបស់ខ្លួន ។ បន្ទាប់មកខ្លួនបានលឺសម្លឹងស្រែកចេញពីក្នុងផ្ទះ ហើយប្រពន្ធខ្លួនក៏បានស្តីបន្ទោសឲ្យជនជាប់ចោទឈ្មោះ [redacted] កុសល ទើបជនជាប់ចោទខឹងក៏បានវាយបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះ ។ ជនជាប់ចោទឈ្មោះ [redacted] កុសល ធ្លាប់មានចិត្តស្រឡាញ់ជនរងគ្រោះ ប៉ុន្តែប្រពន្ធរបស់ខ្លួនបានហាមមិនឲ្យជនជាប់ចោទមកររាយ៉ែរញ៉ៃជាមួយនឹងជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត នៅក្នុងផ្ទះទេ ។ ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើជនជាប់ចោទឈ្មោះ [redacted] កុសល ដោយសារតែជនជាប់ចោទមានកូន៥នាក់នៅក្នុងបន្ទុកត្រូវចិញ្ចឹមបីបាច់ថែរក្សា។ ពេលនេះ កូនទាំង៥នាក់នោះកំពុងស្ថិតនៅក្នុងបន្ទុករបស់ខ្លួនជាអ្នកមើលថែទាំនិងចិញ្ចឹមទាំងអស់។

-សាក្សីឈ្មោះ [redacted] រ៉ូហ្សាមី បានឆ្លើយថា៖ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង២៤និង០០នាទី ខ្លួនអង្គុយលេងនៅមុខផ្ទះ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] កុសល បានចេញទៅនោម ។ បន្ទាប់មកជនជាប់ចោទបានដើរចូលក្នុងផ្ទះវិញតាមទ្វារកណ្តាល ។ ពេលនោះ ខ្លួនបានលឺសម្លេងស្រែករបស់ជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត ដែលជាអ្នកបម្រើការងារក្នុងផ្ទះ ។ ខ្លួនក៏បានស្ទុះចូលទៅក្នុងផ្ទះ ហើយឃើញជនជាប់ចោទឈ្មោះ [redacted] កុសល មានសភាពស្រវឹងស្រាខ្លាំង និងដើរ ទ្រេតពីលើជនរងគ្រោះក្នុងរបៀបលេងសើចជាមួយជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត ផង ។ ពេលនោះ ខ្លួនបានស្តីបន្ទោសជនជាប់ចោទឈ្មោះ [redacted] កុសល ជាច្រើន ទើបជនជាប់ចោទឈ្មោះ [redacted] កុសល ខឹងក៏បានយកដែកវាយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះមួយចំនួន។ ខ្លួនពុំបានដឹងអំពីទំនាក់ទំនងរវាងជនជាប់ចោទឈ្មោះ [redacted] កុសល និងជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត ទេដោយសារអ្នកទាំងពីរខស្បាហ៍លេងសើចជាមួយគ្នា ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមអង្គសវនាការនេះឃើញថា: ជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត បានឆ្លើយបដិសេធនូវចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថាជនជាប់ចោទឈ្មោះ [redacted] កុសល ធ្លាប់បានរំលោភសេពសន្ថវៈ និងគំរាមគំហែងមកលើខ្លួន ។ ប៉ុន្តែពេលនេះ ជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អូស្ណាឡា បានសុំដកពាក្យបណ្តឹងឈប់ប្តឹងមកលើជនជាប់ចោទឈ្មោះ [redacted] កុសល វិញហើយដោយសារពេលនោះជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីបានខឹងនឹងជនជាប់ចោទយ៉ាងខ្លាំង ពីព្រោះជនជាប់ចោទបានផឹកស្រា និងវាយបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងវិញទៀត ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះបានដកពាក្យបណ្តឹងឈប់ប្តឹងជនជាប់ចោទក៏ដោយ តំណាងអយ្យការនៅតែស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចដោយផ្អែកតាមអង្គហេតុដែលបានកើតមានឡើងនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅចំណុចផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី០១ ភូមិ០១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបានប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] កុសល ដដែល ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ៖កូនក្តីខ្លួនបានឆ្លើយយ៉ាងជាក់ច្បាស់និងមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អូស្ណាឡា និងសាក្សីឈ្មោះ [redacted] រ៉ូហ្សាមី ថាកូនក្តីខ្លួនមិនបានប្រព្រឹត្តអំពើ ប៉ុនប៉ងរំលោភសេពសន្ថវៈ មកលើជនរងគ្រោះឈ្មោះ

Scanned with CamScanner

[redacted] សាវ៉ែត នោះទេ ។ រាល់ទង្វើដែលជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត ដែលបានស្រែកឆោឡោនៅថ្ងៃកើតហេតុនោះ គឺដោយសារតែកូនក្តីខ្លួនអោបថើបជនរងគ្រោះ តែមិនបានស៊ីជម្រៅនោះទេ ។ គ្រប់អំពើប៉ះពាល់ ស្មាប និងអង្អែលមករលើជនរងគ្រោះនោះគឺពុំមានធាតុផ្សំក្នុងអំពើ **ប៉ុនប៉ងរំលោភសេពសន្តវៈ** ទេ ។ ដូច្នេះ ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាធ្វើការកែប្រែការចោទប្រកាន់មកលើកូនក្តីខ្លួនពីបទ **ប៉ុនប៉ងរំលោភសេពសន្តវៈ** តាមបញ្ញត្តិមាត្រា**២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌមកជាបទ **ប្រទូស្តកេរខ្មាស** តាមមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌវិញ ។ បន្ថែមពីនេះ ខ្លួនសំណូមរពសុំឲ្យតុលាការមេត្តាផ្តល់ស្ថានសម្រាលដល់ កូនក្តីខ្លួនផងពីព្រោះកូនក្តីខ្លួនត្រូវទទួលបន្ទុកចិញ្ចឹមកូន០៥នាក់តែម្នាក់ឯងដោយសារប្រពន្ធរបស់គាត់បានទទួលមរណភាព និងពុំមានអ្នកមើថែរក្សាកូនទាំង៥នាក់របស់គាត់ ។

<u>សម្តីចុងក្រោយរបស់ជនជាប់ចោទ</u>

ជនជាប់ចោទឈ្មោះ [redacted] កុសល បាននិយាយសម្តីចុងក្រោយថា: ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផងពីព្រោះខ្លួនបានដឹងកំហុសរបស់ខ្លួនហើយ។

<u>សំអាងហេតុ</u>

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាលើសំណុំរឿងបានត្រឹមត្រូវតាមច្បាប់ហើយ

១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] កុសល មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សាវ៉ែត,**ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អូស្តាឡា** និងសាក្សីឈ្មោះ [redacted]**រ៉ូហ្សាមី** ព្រមទាំងភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ថា:កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩វេលាម៉ោង០០ និង៣០នាទី រំលងអធ្រាត្រ នៅចំណុចផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី០១ ភូមិខ១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោ[redacted] កុសល ពិតជាបានអោបថើបជនរងគ្រោះឈ្មោះ [redacted] សាវ៉ែត ដែលកំពុង គេងលង់លក់នៅលើសាឡុងប្រាកដមែន។

អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **កុសល** បានប្រព្រឹត្តពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទ **ប៉ុនប៉ងរំលោភសេពសន្តវៈ** តាមបញ្ញត្តិមាត្រា**២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌទេ។ ហេតុនេះ គប្បីតុលាការធ្វើការកែប្រែការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] កុសល ពីបទ **ប៉ុនប៉ងរំលោភសេពសន្តវៈ** តាមបញ្ញត្តិមាត្រា**២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌមកជាបទ **ប្រទូស្តកេរខ្មាស** តាមមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌវិញ។

២-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **កុសល** បានបង្ហាញឲ្យឃើញថា ជនជាប់ចោទមានចេតនាទុច្ចរិត បង្កឲ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់នីតិរដ្ឋនុកូលភាពសង្គមបំពានលើមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] កុសល ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវអំពើរបស់ខ្លួន ចំពោះមុខក្រមព្រហ្មទណ្ឌជាធរមាន។

៤-តំណាងអយ្យការប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការពិចារណា។

៥-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] កុសល ភេទប្រុស អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៤៤៨ ផ្លូវបេតុង ក្រុមទី០១ ភូមិខ១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌ។

៦-ផ្អែកតាមមាត្រា**៤៧** នៃក្រមព្រហ្មទណ្ឌ បានចែងថា “នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់

ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ” ។

<u>ហេតុដូច្នេះសិនិច្ឆ័យសេចក្តី</u>

១-កែប្រែការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **កុសល** ភេទប្រុស **អាយុ៤៧ឆ្នាំ** សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ**២៤៤៨** ផ្លូវបេតុង ក្រុមទី**០១** ភូមិខ**១** សង្កាត់ច្រាំងចំរេះទី**២** ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៨** ខែកុម្ភៈ ឆ្នាំ**២០១៩** តាមបញ្ញត្តិមាត្រា**២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌ មកជាបទ **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ**២៤៤៨** ផ្លូវបេតុង ក្រុមទី**០១** ភូមិខ**១** សង្កាត់ច្រាំងចំរេះទី**២** ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៨** ខែកុម្ភៈ ឆ្នាំ**២០១៩** តាមបញ្ញត្តិមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌវិញ ។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **កុសល** ភេទប្រុស **អាយុ៤៧ឆ្នាំ** សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំនិង០៦ខែ (មួយឆ្នាំនិងប្រាំមួយខែ)** ពីបទ **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ**២៤៤៨** ផ្លូវបេតុង ក្រុមទី**០១** ភូមិខ**១** សង្កាត់ច្រាំងចំរេះទី**២** ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៨** ខែកុម្ភៈ ឆ្នាំ**២០១៩** តាមបញ្ញត្តិមាត្រា**២៤៦** នៃក្រមព្រហ្មទណ្ឌ ។

៣-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី**២៣** ខែកក្កដា ឆ្នាំ**២០១៩** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **កុសល** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អូស្តាឡា** និងប្រកាសជាសាធារណៈ នៅថ្ងៃទី**៣១** ខែកក្កដា ឆ្នាំ**២០១៩**។ **ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់**។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និង ត្រា	ហត្ថលេខា និងត្រា
[redacted]			

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner